# ទំនាក់ទំនងរវាងការងារ និងភាពក្រីក្រ នៅប្រទេសកម្ពុជា[១]

## សេចក្តីផ្តើម

នៅកម្ពុជា គេឃើញមានភាពខុសគ្នាជាខ្លាំង រវាងកំណើនភាពក្រីក្រ នឹងកំណើន ផសស។ ប្រជាជនក្រីក្រពឹងផ្អែកភាគច្រើនលើកម្លាំងពលកម្ម ដើម្បីរកប្រាក់ចំណូល ហើយដោយសាររចនាសម្ព័ន្ធតាមវិស័យនៃទីផ្សារពលកម្ម ពលករក្រីក្រក៏ស្ថិតក្នុងស្ថានភាពចាញ់ប្រៀប។ កន្លងមកពួកគេទទួលបានតែមួយភាគតូចនៃអត្ថប្រយោជន៍សរុបបានពីកំណើន ដោយសារបាតុភូតនៃការជ្រាបចុះខ្លះៗរបស់វា។ ទោះបីជនក្រីក្រមួយភាគធំមានការងារធ្វើក្តី ប៉ុន្តែពួកគេស្ថិតក្នុងសេដ្ឋកិច្ចក្រៅផ្លូវការ ដូច្នេះតែងពុំមានប្រាក់ចំណូលគ្រប់គ្រាន់ ឬក៏សុវត្ថិភាពការងារទេ (Bell and Newitt 2010)។ វិស័យកសិកម្មនៅតែចម្បងគេបើគិតពីសមត្ថភាពស្រូបយកយកកម្លាំងពលកម្ម (៦៩% នៃកម្លាំងពលកម្មសរុប) ប៉ុន្តែបើពិនិត្យតាមអត្រាកំណើនត្រឹម ៤,៨% ក្នុងអំឡុងពេលពីឆ្នាំ ២០០០ ដល់ ២០១១ កសិកម្មមានការលូតលាស់យឺតជាងវិស័យឯទៀត។ វិស័យឧស្សាហកម្មបានរីកចម្រើនយ៉ាងលឿន ប៉ុន្តែស្រូបយកបានត្រឹម ៩,១% នៃកម្លាំងពលកម្មសរុបប៉ុណ្ណោះ។ ដូច្នេះរចនាសម្ព័ន្ធការងារនៅកម្ពុជា មិនមានការផ្លាស់ប្តូរខ្លាំងទេ។ កម្លាំងពលកម្មនៅតាមជនបទភាគច្រើន រកបានការងារក្នុងសកម្មភាពផ្សេងៗ ដែលមានផលិតភាពទាប ហើយជាច្រើននាក់គ្មានការងារធ្វើ ឬមានការងារធ្វើមិនពេញលេញ។ អ្នកបម្រើការងារមានប្រាក់ឈ្នួលទាប មានឱកាសតិចតួចណាស់នឹងបានចាកផុតពីភាពក្រីក្រឬធ្វើវិនិយោគដើម្បីពង្រីកឱកាសការងារឬបើកអាជីវកម្មផ្ទាល់ខ្លួន។ ជាលទ្ធផល ក្នុងឆ្នាំ២០១១ ភាពក្រីក្រនៅមានកម្រិតខ្ពស់រហូតដល់ ១៩,៨% (MOP 2012)។

អត្ថបទនេះ[២] ព្យាយាមពិនិត្យស្រាវជ្រាវពីចំណងទាក់ទងរវាងរចនាសម្ព័ន្ធទីផ្សារពលកម្មនិងការងារ ហើយនិងស្ថានភាពក្រីក្រនៅកម្ពុជា។ អ្នកនិពន្ធបានប្រើ ការវិភាគបែបពណ៌នានៃលទ្ធភាពកើនការងារទៅតាមកំណើន សេដ្ឋកិច្ច(Employment elasticity of growth) ផលិតភាពកម្លាំងពលកម្ម និងកំណើនប្រាក់ឈ្នួលពិត ដើម្បីបង្ហាញពីរចនាសម្ព័ន្ធ និងនិន្នាការនៃទីផ្សារពលកម្ម, និងបានប្រើ ការប៉ាន់ស្មាន Probit ដើម្បីបង្ហាញពីចំណងទាក់ទងរវាងការងារក្នុងវិស័យកសិកម្មនិងឧស្សាហកម្ម ហើយនិងវត្តមានភាពក្រីក្រ។

## វិធីសាស្ត្រ

ម៉ូដែល Probit[៣] បានយកចេញមកពីការសិក្សារបស់ Jemio and Choque (2003), Huong *et al.* (2003) និង Krongkaew *et al.* (2006) ដើម្បីពិនិត្យពីទំហំឥទ្ធិពលការងារទៅលើភាពក្រីក្ររបស់គ្រួសារ។ សមីការនៃម៉ូដែលនេះ អាចសរសេរជា:

$$Y = \alpha + \beta E + \sum \pi X + \varepsilon$$

ដែលក្នុងនេះ y គឺ ប្រូបាប៊ីលីតេក្លាយជាអ្នកក្រីក្រ, E តំណាងឲ្យស្ថានភាពការងារគ្រួសារ (ដែលស្មើនឹង ១ ប្រសិនបើមេគ្រួសារមានការងារធ្វើក្នុងវិស័យកសិកម្ម និងស្មើ 0 បើគាត់មានការងារធ្វើក្នុងវិស័យឧស្សាហកម្ម), និង X តំណាងឲ្យជាអាទិ៍ លក្ខណៈនៃមេគ្រួសារ (អាយុ ការអប់រំ ភេទ និងការងារមានប្រាក់ឈ្នួល), តំបន់, ទំហំគ្រួសារ សមាជិកគ្រួសារក្នុងក្រុមអាយុខុសៗគ្នា, ចំនួនម៉ោងធ្វើការជាមធ្យមក្នុងមួយថ្ងៃ, ចំណូលក្នុងកសិដ្ឋាន និងក្រៅកសិដ្ឋាន និងទំហំដី។

របាយការណ៍នេះប្រើប្រាស់ទិន្នន័យម៉ាក្រូ និងមីក្រូចម្រុះគ្នាសម្រាប់ការវិភាគបែបពិពណ៌នា រីឯទិន្នន័យគ្រួសារបានពី អង្កេតសេដ្ឋកិច្ចសង្គមកិច្ចកម្ពុជា (CSES) បានយកមកប្រើប្រាស់ក្នុងការធ្វើម៉ូដែល Probit។

## ស្ថានភាពការងារ

សម្រាប់ការស្រាវជ្រាវនេះ ភាពមានការងារធ្វើត្រូវបានកំណត់ជា ការងារមានរយៈពេលយ៉ាងហោចណាស់ មួយម៉ោងក្នុងមួយសប្តាហ៍ (NIS 2011) ទោះក្នុងមុខងារអ្វីក៏ដោយ។ ជាមធ្យមក្នុងរយៈពេល ១០ឆ្នាំ មកដល់ឆ្នាំ២០១១ មាន ៨៣% នៃកម្លាំងពលកម្មសរុបនៅកម្ពុជាបានចូលរួមក្នុងការងារ គឺស្មើនឹង ៥៤% នៃប្រជាជនសរុប។ ៦០% នៃពលករទាំងនេះធ្វើការក្នុងវិស័យកសិកម្ម, ២៦% ក្នុងសេវាកម្ម និង ១៤% ក្នុងឧស្សាហកម្ម។ ក្នុងចំណោមពលករក្នុងវិស័យឧស្សាហកម្ម មាន ៦២% ធ្វើការក្នុងផ្នែកកម្មន្តសាល។ កម្លាំងពលកម្មកើនឡើង ៣,៣% ក្នុងមួយឆ្នាំៗ។ ឱកាសការងារជាផ្លូវការថ្មីៗបានកើនឡើងក្នុងអត្រាប៉ុនគ្នានឹងកម្លាំងពលកម្ម ចាប់តាំងពីឆ្នាំ២០០៩ មក ហើយវាកើនឡើងក្នុងអត្រាខ្ពស់ជាងដល់ ៣,៦% បើសិនគេបូកបញ្ចូលទាំងបណ្តាឆ្នាំពីមុនឆ្នាំ២០០៩ ផង។ អត្រាបង្កើតការងារ មិនទាន់គ្រប់គ្រាន់ ដើម្បីផ្តល់ការងារដល់កម្លាំងពលកម្មទាំងមូលនោះទេ។ ទោះយ៉ាងនេះក្តី អត្រាគ្មានការងារធ្វើជាមធ្យមមានកម្រិតទាប ត្រឹម ១,១% ដោយសារការកំណត់និយមន័យធំទូលាយនៃភាពមានការងារធ្វើ ដែលបានយកការងារ ទាំងអស់មកបូកបញ្ចូល សូម្បីការងារដែលគេចាត់ទុកថា"ងាយរងគ្រោះ"ពោលគឺគ្មានស្ថិរភាព ឬគ្មានបទបញ្ញត្តិគ្រប់គ្រង។ ចំនួនស្ត្រីចូលរួមក្នុងសកម្មភាពសេដ្ឋកិច្ចនៅមានកម្រិតទាបត្រឹម ៧៨% នៃកម្លាំងពលកម្មស្ត្រីសរុប រីឯអត្រាសម្រាប់បុរសគឺ ៨៦% ។ មូលហេតុមួយនៃស្ថានភាពនេះ គឺស្ត្រីនៅចំណាយពេលច្រើនទៅលើការងារក្នុងផ្ទះ ដែលគេតែងចាត់ទុកជា ភារកិច្ចរបស់ស្ត្រី។

---

១ រៀបរៀងដោយ ផាន់ ដាលីស ជាអ្នកស្រាវជ្រាវក្នុងកម្មវិធីសេដ្ឋកិច្ច ពាណិជ្ជកម្ម និងសមាហរណកម្មក្នុងតំបន់។

២ អត្ថបទនេះផ្អែកលើ លទ្ធផលនៃការសិក្សាមួយ (ចេញផ្សាយក្នុងពេលឆាប់ៗ) ដែលស្ថិតក្នុងគម្រោងស្រាវជ្រាវពីកំណើនសម្រាប់គ្រប់គ្នា ផ្តល់មូលនិធិដោយ Sida។

៣ ម៉ូដែល Probit គឺជាប្រូបាប៊ីលីតេដែលអថេរជាផលមួយ (មានតម្លៃតែពីរ: ក្នុងករណីនេះ គឺ គ្រួសារ ធូរធារ ឬក៏ ក្រីក្រ) វាផ្លាស់ប្តូរ នៅពេលមានការផ្លាស់ប្តូរក្នុងតម្លៃនៃកត្តាជាដើមហេតុ។

រូបភាព ១៖ ការងារមានប្រាក់ឈ្នួលរបស់បុរស និងស្ត្រី គិតតាមវិស័យ (%)




ប្រភព៖ World Development Indicator

ឱកាសការងារនៅតំបន់ជនបទ មានច្រើនជាងនៅតំបន់ទីក្រុង។ យោងតាម CSES ប្រជាជន មានការងារធ្វើនៅតំបន់ជនបទ តំណាងឲ្យជាមធ្យម ៦៨% នៃកម្លាំងពលកម្មសរុបនៅតាមជនបទក្នុងអំឡុងឆ្នាំ២០០៤ ដល់ ២០១១ ចំណែកឯនៅទីក្រុងមានត្រឹម ៥៧% ។ ក្នុងចំណោមពលករនៅតំបន់ជនបទ មាន ៥៩% ចូលរួមក្នុងវិស័យកសិកម្ម, ៩,៨% ក្នុងកម្មន្តសាល, ៩,៥% ក្នុងពាណិជ្ជកម្ម និងប្រហែល ២១% ក្នុងវិស័យផ្សេងៗទៀត។ ការងារភាគច្រើននៅទីក្រុង ស្ថិតក្នុងវិស័យពាណិជ្ជកម្ម (២៨%), កសិកម្ម (១៦%), កម្មន្តសាល (១១%), រដ្ឋបាលសាធារណៈ និងការពារជាតិ (៨%) និង វិស័យដទៃទៀត (៣៧%)។

## ភាពយឺតការងារ នៃកំណើន

ភាពយឺតការងារ ឬអាំងតង់ស៊ីតេការងារ នៃកំណើន (Employment elasticity or employment intensity of growth) បង្ហាញពី បែបបទដែលការផ្លាស់ប្តូរក្នុងធាតុចេញតាមវិស័យ ធ្វើឲ្យប្រែប្រួលដល់ឱកាសការងារ ពោលគឺ ទំហំដែលឱកាសការងារទទួលរងឥទ្ធិពលពីការផ្លាស់ប្តូរនៃ ផសស តាមវិស័យ និងបញ្ច្រាស់មកវិញ។ ពីឆ្នាំ១៩៩៥ ដល់ ១៩៩៨ ភាពយឺតជារួមគឺខ្ពស់ជាង មួយឯកតា (ការងារ កើនឡើង លឿនជាង ធាតុចេញ ឬ ឱកាសការងារកើនឡើងច្រើនជាង ១០% ប្រសិនបើ ផសស (GDP) កើនឡើង ១០%)។ ក្នុងអំឡុងពេលនោះគេឃើញថា សម្រាប់វិស័យឧស្សាហកម្ម កំណើនការងារមានលក្ខណៈល្អ ប៉ុន្តែ កំណើនផលិតភាពនៅទាប។ វិស័យកសិកម្ម និងសេវាកម្ម ស្រូបយកពលករបានជាច្រើន ហើយពលកម្មក៏មានផលិតភាពខ្ពស់ស្របតាមនោះដែរ (តារាង ១)។

សមីការខាងក្រោមនេះបង្ហាញពី ទំនាក់ទំនងរវាងភាពយឺតការងារនៃធាតុចេញ និងការផ្លាស់ប្តូរក្នុងផលិតភាពការងារ៖

$$\varepsilon_i = \frac{\Delta E}{\Delta Y} = \frac{(E_{it} - E_{i(t-1)})/E_{i(t-1)}}{(Y_{it} - Y_{i(t-1)})/Y_{i(t-1)}}$$

$$\varepsilon_i = 1 - \frac{\Delta P}{\Delta Y}$$

$$\Delta P = (1 - \varepsilon)\Delta Y$$

ដែលក្នុងនោះ ε ជាភាពយឺតការងារនៃធាតុចេញ (Employment elasticity of output), E តំណាងឲ្យការងារ, y តំណាងឲ្យទិន្នផល, i ជាវិស័យ, t ជាពេលវេលា, និង P ជាផលិតភាព។

ចាប់ពីឆ្នាំ២០០៨ ដល់ ២០១១ ភាពយឺតការងារនៃកំណើនធាតុចេញក្នុងវិស័យកសិកម្ម មានលក្ខណៈអវិជ្ជមានខ្លាំងណាស់ ដល់ ៥៥,៨ និង អវិជ្ជមានក្នុងសេវាកម្ម ត្រឹម ៣,៦។ នេះជាលទ្ធផលនៃវិបត្តិហិរញ្ញវត្ថុសកល និងផលអាក្រក់ក្រោយពីនោះ។ តារាង ១ បង្ហាញថា មានតែឧស្សាហកម្មប៉ុណ្ណោះដែលសឹងតែគ្មានរងឥទ្ធិពលអ្វីពីវិបត្តិដោយមានភាពយឺតជាវិជ្ជមានដល់ ២,៤ ។ វិស័យនេះគេចាត់ទុកថា ជំរុញឡើងដោយកម្លាំងពលកម្មជាជាង ជំរុញឡើងដោយផលិតភាព ដូចមានតួលេខនៃភាពយឺតបញ្ជាក់ស្រាប់។ ផ្ទុយទៅវិញ វិស័យកសិកម្ម និងសេវាកម្ម ត្រូវបានជំរុញដោយផលិតភាព ជាជាង ដោយចំនួនប្រជាជនដែលវិស័យទាំងនេះជួលប្រើ។ បុរសមានឱកាសទទួលបានការងារច្រើនជាងស្ត្រី។ យោងតាមនិន្នាការពិនិត្យឃើញពីឆ្នាំ២០០៨ ដល់

តារាង ១៖ ភាពយឺតការងារតាមវិស័យនៃកំណើនធាតុចេញ (Sectoral Employment Elasticity of Output Growth) (ក្នុងអំឡុងពេលជ្រើសរើស)

| | 1995-98 | 1999-2003 | 2004-07 | 2008-11 | 2008-11 (ក្រៅពី 2009) |
|---|---|---|---|---|---|
| កសិកម្ម | 0.78 | 0.44 | 0.09 | -55.76 | 0.34 |
| ឧស្សាហកម្ម | 4.33 | 6.91 | -2.71 | 2.39 | -2.15 |
| សេវាកម្ម | 0.99 | 1.03 | 0.71 | -3.65 | -3.48 |
| សរុប | 1.01 | 0.74 | 0.39 | -0.16 | -0.36 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើ NIS 2011; IMF 2009; World Bank-WDI, 1995-2011

តារាង ២៖ ផលិតភាពពលកម្មតាមវិស័យ (ដុល្លារ/ម៉ោង/ពលករ, គិតតាមឆ្នាំជ្រើសរើស)

| | 1997 | 1998 | 2000 | 2001 | 2004 | 2007 | 2008 | 2009 | 2010 | 2011 |
|---|---|---|---|---|---|---|---|---|---|---|
| កសិកម្ម | 0.22 | 0.17 | 0.14 | 0.15 | 0.18 | 0.25 | 0.24 | 0.30 | 0.32 | 0.33 |
| ឧស្សាហកម្ម | 1.19 | 0.94 | 0.75 | 0.53 | 0.61 | 0.62 | 1.36 | 0.68 | 0.70 | 0.75 |
| សេវាកម្ម | 0.82 | 0.40 | 0.64 | 0.49 | 0.43 | 0.46 | 0.94 | 0.64 | 0.57 | 0.65 |
| ជាមធ្យម | 0.37 | 0.26 | 0.28 | 0.27 | 0.32 | 0.39 | 0.50 | 0.48 | 0.48 | 0.51 |

ប្រភព៖ ការគណនារបស់អ្នកនិពន្ធផ្អែកលើ NIS 2011; IMF 2009; CSES, 2004-2011; World Bank-WDI, 1998-2011

២០១១ បើសិន ផសស កើនឡើង ១០% កំណើនការងារដែលពលករបុរសទំនងទទួលបានគឺ ៧,២% នៃកម្លាំងពលកម្មបុរសសរុប ធៀបនឹង ៦,៥% សម្រាប់ពលករជាស្ត្រី។

## ផលិតភាពពលកម្ម និងកំណើនប្រាក់ឈ្នួលពិត

ពីឆ្នាំ២០០៨ ដល់ ២០១១ ពលកម្មតំណាងឲ្យជាមធ្យម ៦៦% នៃធាតុចូលសម្រាប់វិស័យសេវាកម្ម, ៥៤% នៃធាតុចូលសម្រាប់វិស័យកសិកម្ម, និង ៤៣% នៃធាតុចូលសម្រាប់ឧស្សាហកម្ម។ តួលេខនេះគូសបញ្ជាក់ពី សារៈសំខាន់នៃកំណើនផលិតភាពពលកម្ម ក្នុងលក្ខណៈជាធនធានសេដ្ឋកិច្ចសម្រាប់កំណើនធាតុចេញ ដែលជួយលើកកម្ពស់ភាពប្រកួតប្រជែងរបស់ក្រុមហ៊ុន (Krugman 1994)។

ក្នុងឆ្នាំ២០១១ ការងារកសិកម្មផ្តល់ផល ០.៣៣ដុល្លារក្នុងមួយម៉ោង ឬកើនលើសពីទ្វេដង បើធៀបនឹងឆ្នាំ២០០០ (តារាង ២)។ កំណើននេះទទួលបានជាចម្បងផងដែរមកពី ការផ្លាស់ប្តូរក្នុងធាតុចូល ដូចជា គ្រាប់ពូជល្អជាងមុន និងការប្រើប្រាស់ជីថ្នាំសម្លាប់សត្វចង្រៃ និងគ្រឿងម៉ាស៊ីន។ ផលិតភាពពលកម្មក្នុងសេវាកម្ម គឺ ០,៦៥ដុល្លារក្នុងមួយម៉ោង ឬកើនឡើងបន្តិចបន្តួចធៀបនឹងត្រឹម ០,៦៤ដុល្លារក្នុងឆ្នាំ២០០០។ ផលិតភាពពលកម្មក្នុងវិស័យឧស្សាហកម្មបានខ្ពស់ជាងគេ ដល់ ០,៧៥ដុល្លារក្នុងមួយម៉ោង ប៉ុន្តែពុំបានជំរុញកំណើន ឧស្សាហកម្មនោះទេ ពីព្រោះវាតំណាងឲ្យការប្រើប្រាស់គ្មានប្រសិទ្ធភាពនូវកម្លាំងពលកម្មដែលសមត្ថភាពនៅមានកម្រិតនៅឡើយ។

ដើម្បីលើកកម្ពស់គុណភាពជីវិតរបស់ប្រជាជន កម្ពុជាមិនត្រឹមតែត្រូវការឱកាសការងារប៉ុណ្ណោះទេ ប៉ុន្តែក៏ត្រូវការផងដែរនូវការងារមានប្រាក់ឈ្នួលត្រឹមត្រូវ។ CSES បានរកឃើញថាប្រាក់ឈ្នួលពិតប្រចាំខែរបស់ពលករក្នុងកសិកម្ម មានជាមធ្យម ២២៨.០៣៦រៀល (៥៦ដុល្លារ) ក្នុងឆ្នាំ២០១១ ក្នុងឧស្សាហកម្មមានជាមធ្យម ៣៧៥.៣៦២រៀល (៩៣ដុល្លារ) និងក្នុងសេវាកម្ម ៥៣៤.៤៦៤រៀល (១៣២ដុល្លារ)។ ប្រាក់ឈ្នួលកើនជាមធ្យម ៤១% ក្នុងវិស័យកសិកម្ម, ១៥% ក្នុងឧស្សាហកម្ម, និង ១១% ក្នុងសេវាកម្ម ក្នុងអំឡុងឆ្នាំ២០០៧ ដល់ ២០១១។ ប្រជាជនរស់នៅក្នុងរាជធានីភ្នំពេញ ពឹងផ្អែកជាខ្លាំងលើ ការងារមានប្រាក់ឈ្នួលដែលតំណាងឲ្យ ៥៧% នៃប្រភពប្រាក់ចំណូលសរុបសម្រាប់គ្រួសារ នៅក្នុងតំបន់នោះ ធៀបនឹងត្រឹម ២៥% សម្រាប់អ្នករស់នៅក្នុងតំបន់ផ្សេរ។

លទ្ធផលរកឃើញជាក់ស្តែងនៅឆ្នាំ២០០៧ គ្រួសារចូលរួមក្នុងវិស័យកសិកម្មមានឱកាសក្លាយជាអ្នកក្រ ១១% ខ្ពស់ជាងអ្នកចូលរួមក្នុងវិស័យឧស្សាហកម្ម។ ឱកាសក្លាយជាអ្នកក្រនេះបានថយចុះក្នុងឆ្នាំ២០០៩ រហូតនៅត្រឹម ២,៤%។ អត្រាភាពក្រីក្រមិនអាចកំណត់បានដោយផ្អែកលើ ទិន្នន័យសម្រាប់ឆ្នាំ ២០១០ និង ២០១១ នោះទេ។ នៅពេលធ្វើអង្កេត CSES មួយលើកៗ គេអាចមើលឃើញថា បើឆ្នាំសិក្សាអប់រំរបស់មេគ្រួសារកើនឡើងមួយឆ្នាំ ភាពក្រីក្ររបស់គ្រួសារថយចុះអស់ ១,៨%។ ម្យ៉ាងទៀត គ្រួសារដែលមានដីយ៉ាងហោចណាស់ ១,២ហិកតាមិនសូវក្លាយជាអ្នកក្រទេ គឺដូចគ្នានឹង គ្រួសារដែលមានសមាជិកច្រើនក្នុងអាយុពី ១៨ ដល់ ៦៤ឆ្នាំ។ ផ្ទុយទៅវិញ គ្រួសារធំៗ (មានសមាជិក ៤,៧នាក់ ឬលើសពីនេះ និងមានសមាជិកច្រើនមានអាយុក្រោម ១៨ឆ្នាំ) អាចងាយនឹងក្លាយជាអ្នកក្រ។

សេចក្តីសន្និដ្ឋាន ទីផ្សារការងារកម្ពុជានៅមានមូលដ្ឋានតូចចង្អៀត ក្នុងនោះបុរសបានគ្របដណ្តប់លើឱកាសការងារនានា។ ទោះយ៉ាងនេះក្តី ការចូលរួមរបស់ស្ត្រីក្នុងសកម្មភាពសេដ្ឋកិច្ចកំពុងកើនឡើងក្នុងគ្រប់វិស័យ។ គេរកឃើញថា វិស័យឧស្សាហកម្មមានកំណើនជំរុញឡើង ដោយកម្លាំងពលកម្ម និងមានផលិតភាពពលកម្មខ្ពស់ជាងក្នុង វិស័យកសិកម្មនិងសេវាកម្មដែលមានកំណើនជំរុញឡើងដោយផលិតភាព។ ពលកម្មក្នុងវិស័យកសិកម្ម និងសេវាកម្ម ងាយទទួលឥទ្ធិពលពីវិបត្តិផ្សេងៗ ដូចបានសង្កេតឃើញក្នុងអំឡុងពេលមានវិបត្តិហិរញ្ញវត្ថុ និងផលអាក្រក់តាមក្រោយក្នុងឆ្នាំ២០០៩។ ម្យ៉ាងទៀត អ្នកបម្រើការងារក្នុងវិស័យកសិកម្ម មានប្រូបាបប៊ីលីតេក្លាយជាអ្នកក្រ ខ្ពស់ជាងអ្នកបម្រើការងារក្នុងវិស័យផ្សេងទៀត ហើយកត្តាដែលជួយឲ្យគ្រួសារគេចផុតពីភាពក្រីក្រ មានជាសំខាន់ កម្មសិទ្ធិដីធ្លី និងការអប់រំ។

ដូច្នេះមតិលើកឡើងសម្រាប់គោលនយោបាយម៉ាក្រូ រួមមានការពង្រីកលទ្ធភាពមានដីកសិកម្មប្រើប្រាស់ តាមការចងក្រងឯកសារឲ្យបានត្រឹមត្រូវនិងមានសមធម៌ ការធ្វើផែនទី និងការផ្តល់កម្មសិទ្ធិដីធ្លី។ មធ្យោបាយនេះអាចជួយជំរុញផលិតកម្មដំណាំ និងពង្រីកសកម្មភាពសេដ្ឋកិច្ច ក្នុងការកែច្នៃ ឬលក់រាយ។ សកម្មភាពទាំងនេះជួយបង្កើតការងារក្នុងកសិដ្ឋាន និងនៅក្រៅកសិដ្ឋាន។ ការផ្តល់លទ្ធភាពឲ្យប្រជាជនទទួលបានការអប់រំកាន់តែច្រើនមានសារៈសំខាន់ណាស់ ហើយវិនិយោគសាធារណៈបន្ថែម គួរលៃចែកជាពិសេសសម្រាប់ការអប់រំកម្រិតមធ្យមសិក្សាបឋមភូមិ និងមធ្យមសិក្សាទុតិយភូមិ។ ការពង្រីកថវិកា ក៏គួរមានបែងចែកទៅឲ្យកម្រិតបឋមសិក្សា និងមធ្យមសិក្សាបឋមភូមិ ដូចបានលើកឡើងដោយលោក Tong and Phay (ចេញផ្សាយក្នុងពេលឆាប់ៗ)។

## ឯកសារយោង


Bell, S. and K. Newitt (2010), Decent Work and Poverty Eradication: Literature Review and Two Country Study (London: Ergon Associates)

CSES (2004-2011), Cambodia Socio-Economic Survey (Phnom Penh: Cambodia National Institute of Statistics)

Huong L.P., Tuan Q.B. and Minh H.D. (2003), Employment Poverty Linkages and Policies for Pro-poor Growth in Vietnam (Hanoi: Institute of World Economy)

IMF, International Monetary Fund (2009), Cambodia: Statistical Appendix, IMF Country Report 09/48 (Washington, DC: IMF)

Jemio, C.L and C.M. Choque (2003), Employment-poverty Linkages and Policies: The Case of Bolivia (Geneva: International Labour Office)

Krongkaew, M., S. Chamnivickorn and I. Nitithanprapas (2006), "Economic Growth, Employment and Poverty Reduction Linkages: The Case of Thailand", Issues in Employment and Poverty Discussion Paper 20 (Geneva: ILO)

Krugman, P. (1994), *The Age of Diminished Expectations* (New York: Norton & Company)

MOP, Ministry of Planning (2012), *Annual Progress Report* (Phnom Penh: MOP)

NIS, National Institute of Statistics (2011), *Statistical Yearbook of Cambodia 2011* (Phnom Penh: NIS)

Phann, D. (forthcoming), The *Links between Employment and Poverty: Cambodia*, Working Paper Series (Phnom Penh: CDRI)

Tong K. and Phay S. (forthcoming), "Inclusiveness and Spending on Public Education in Cambodia", *Annual Development Review 2013-14* (Phnom Penh: Cambodia Development Resource Institute)

World Bank (2014), "World Development Indicators", http://data.worldbank.org/data-catalog/-world-development-indicators


# តាមដានសេដ្ឋកិច្ច - ស្ថានភាពក្រៅប្រទេស[១]

ផ្នែកនេះរៀបរាប់ពី សូចនាករនៃសេដ្ឋកិច្ចពិភពលោកសំខាន់ៗ និង សេដ្ឋកិច្ចនៅអាស៊ីខាងត្បូង និងខាងកើត។

កំណើនសេដ្ឋកិច្ចនៅអាស៊ី និងប្រទេសឧស្សាហកម្មមួយចំនួន មានស្ថិរភាពឡើងវិញនៅឆ្នាំ២០១២។ ដូច្នេះការងារនៅសល់ត្រូវបន្តដោះស្រាយ គឺការស្តារឡើងវិញនូវទំនុករបស់អ្នកប្រើប្រាស់ និងវិនិយោគិន ឲ្យដល់កម្រិតនៅមុនពេលមានវិបត្តិ និងខ្ពស់ជាងនោះទៀត។ អាស៊ីនៅតែជាកម្លាំងជំរុញកំណើនក្នុងពិភពលោកបន្តទៀត នៅពេលដែលបណ្តាប្រទេសអភិវឌ្ឍន៍ចម្បងៗកំពុងព្យាយាមងើបឡើងវិញ។

នៅឆ្នាំ២០១២ ផសស ពិត នៅឥណ្ឌូនេស៊ី មានកំណើនជាមធ្យម ៦,០% ទោះបីជាមានការធ្លាក់ចុះបន្តិច ក្នុងត្រីមាសទី៤ ឆ្នាំ២០១២ ដល់ ៦,១% ធៀបនឹង កម្រិត ៦,៥% នៅត្រីមាសដូចគ្នាកាលពីឆ្នាំមុន។ ផសស នៅម៉ាឡេស៊ីកើន ៦,៤% ធៀបនឹងមួយឆ្នាំមុន រីឯ ផសស នៅសិង្ហបុរី ធ្លាក់កំណើនមកត្រឹម ១,៥% ធៀបនឹង ៣,៦% ក្នុងរយៈពេលដូចគ្នាកាលពីឆ្នាំមុន។ ថៃសម្រេចបានកំណើនប្រចាំឆ្នាំខ្ពស់ណាស់ ដល់ទៅ ១៩,៥% នៅត្រីមាសទី៤ ដោយសារចំណាយប្រើប្រាស់ក្នុងស្រុក និងការនាំចេញកើនឡើងយ៉ាងខ្លាំង។ កំណើននៅចិន ថយចុះ ប៉ុន្តែនៅតែខ្ពស់ដល់ ៧,៩% នៅត្រីមាសទី៤ ។ ភាពតានតឹងខាងនយោបាយ និងយោធា រវាងចិន និងជប៉ុន លើបញ្ហាកោះតូចៗមួយចំនួន មិនបានធ្វើឲ្យខូចខាតដល់សេដ្ឋកិច្ចចិនទេ ហើយការតាំងចិត្តរបស់ប្រទេសទាំងពីរក្នុងការដោះស្រាយជម្លោះដោយសន្តិភាព អាចជះឥទ្ធិពលធ្វើឲ្យកំណើនមានស្ថិរភាព។ នៅត្រីមាសទី៤ កំណើន ផសស ប្រចាំឆ្នាំ នៅហុងកុង ធ្លាក់ចុះមកត្រឹម ២,៥% ធៀបនឹងកម្រិត ៣,០% ក្នុងពេលដូចគ្នាកាលពីឆ្នាំមុន រីឯកំណើន ផសស នៅកូរ៉េ គឺ ១,៦%។

កំណើនក្នុងប្រទេសអ្នកមាន ជាពិសេសនៅតំបន់អឺរ៉ូ នៅតែបន្តឡើងចុះ ដោយសារអន្តរាគមន៍សេដ្ឋកិច្ចមិនបានផ្តល់លទ្ធផលគួរជាទីពេញចិត្ត។ នៅត្រីមាសទី៤ សេដ្ឋកិច្ចតំបន់អឺរ៉ូបានធ្លាក់ចុះយ៉ាងខ្លាំង ដោយមានកំណើន ផសស អវិជ្ជមាន (-0,៩%) ដល់ទៅ ៣ត្រីមាសជាបន្តបន្ទាប់ និង កំណើនសូន្យនៅត្រីមាសទី១។ បញ្ហាវិបត្តិធនាគារ បន្តរីករាលដាល ហើយថ្មីៗនេះបានរាលដាលដល់ប្រទេស Cyprus។ កំណើននៅសហរដ្ឋអាមេរិក មានស្ថិរភាពឡើងវិញ ដោយសេដ្ឋកិច្ចមានអត្រាកំណើនប្រចាំឆ្នាំ ១,៦% នៅត្រីមាសទី៤ និងបានបង្កើតការងារជាច្រើនថែមទៀត។ ប៉ុន្តែ អ្នកបង្កើតគោលនយោបាយ និងរដ្ឋាភិបាល នៅតែត្រូវចរចាគ្នាដោះស្រាយឲ្យបាននូវបញ្ហាថវិកាសម្រាប់ឆ្នាំសារពើពន្ធ និងតុល្យភាពថវិកា ដើម្បីរក្សា

[១] អត្ថបទនេះ រៀបរៀងដោយលោក រ័ត្ន វឌ្ឍនា ជាអ្នកស្រាវជ្រាវនៅវិទ្យាស្ថាន CDRI។